ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១០ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការហាមឃាត់ការប្រើប្រាស់ ការផ្សព្វផ្សាយពាណិជ្ជកម្ម ការតាំងលក់ផលិតផលថ្នាំជក់ និងកិច្ចសហការជាមួយឧស្សាហករថ្នាំជក់

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា សង្កេតឃើញថា គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនជាច្រើន បានគោរពនិងអនុវត្តតាមស្មារតីនៃសេចក្តីណែនាំលេខ៣១ អយក.សណន ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការហាមឃាត់ការប្រើប្រាស់ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការតាំងលក់និងប្រើប្រាស់ផលិតផលថ្នាំជក់ និងគ្រឿងស្រវឹងក្នុងបរិវេណគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន បានល្អប្រសើរ ប៉ុន្តែនៅមានគ្រឹះស្ថានសិក្សាមួយចំនួនតូចមានការភ្លាំងភ្លាត់ ឬយល់ច្រឡំក្នុងការកៀរគរការគាំទ្រពីសប្បុរសជនជាឧស្សាហករថ្នាំជក់ បណ្តាលឱ្យមានការប្រើប្រាស់ស្លាកសញ្ញាពាណិជ្ជកម្ម តាំងនៅក្នុងកម្មវិធីនានារបស់គ្រឹះស្ថានសិក្សាខ្លួន។

ក្នុងស្មារតីខាងលើ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់អង្គភាពចំណុះក្រសួង សាកលវិទ្យាល័យ វិទ្យាស្ថាន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាគ្រប់កម្រិតទាំងសាធារណៈនិងឯកជន ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោមៈ

១.ត្រូវកំណត់និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ស្តីពីការហាមឃាត់ការប្រើប្រាស់ ការបង្ហុយផ្សែងផលិតផលថ្នាំជក់គ្រប់ប្រភេទ ការតាំងលក់ ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់នៅជុំវិញខាងក្រៅបរិវេណនិងក្នុងបរិវេណគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន។

២.ត្រូវអនុវត្តដោយការយកចិត្តទុកដាក់ខ្ពស់ ធ្វើការអប់រំ ផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធគ្រោះថ្នាក់បង្កដោយការប្រើប្រាស់ ការហឺតផ្សែងផលិតផលថ្នាំជក់គ្រប់ប្រភេទ។

៣.មិនត្រូវចាប់ដៃគូសហការជាមួយឧស្សាហករថ្នាំជក់ ទោះក្នុងគោលបំណងណាមួយជាអាទិ៍ សកម្មភាព សប្បុរសធម៌ ទស្សនកិច្ចសិក្សា ហាត់ការងារ ផ្លាស់ប្តូរបទពិសោធន៍ ឬសិក្សាស្រាវជ្រាវ។

៤.មិនត្រូវទទួលការឧបត្ថម្ភគាំទ្រ ឬចុះអនុស្សរណៈយោគយល់គ្នាជាមួយឧស្សាហករថ្នាំជក់ ដើម្បីគាំទ្រដល់សកម្មភាពអប់រំតាមគ្រប់រូបភាព។

៥.មិនអនុញ្ញាតឱ្យផ្តល់ទីកន្លែង ឬទីធ្លាគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន សម្រាប់រៀបចំកម្មវិធីផ្សព្វផ្សាយ ឬពិពណ៌ដែលជាកម្មវិធីរបស់ឧស្សាហករថ្នាំជក់។

៦.ត្រូវចូលរួមលុបបំបាត់សកម្មភាពប្រើប្រាស់ផលិតផលថ្នាំជក់តាមគ្រប់រូបភាព។ ចំពោះគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនណាដែលអនុវត្តផ្ទុយពីខ្លឹមសារខាងលើ ត្រូវបញ្ឈប់កិច្ចសហការ សកម្មភាពផ្សព្វផ្សាយជាបន្ទាន់ និងកែតម្រូវឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ទទួលបានសេចក្ដីណែនាំនេះ សូម ឯកឧត្ដម លោកជំទាវ លោក លោកស្រី សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន ប្រធានអង្គភាព ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយកគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ត្រូវអនុវត្ត សេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ៧កើត៦កើត៨ ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល ៖**

- ក្រសួងសុខាភិបាល
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពចំណុះទីស្ដីការក្រសួង អ.យ.ក.
- រដ្ឋបាលរាជធានី ខេត្ត

*"ដើម្បីជូនជ្រាបនិងសហការ"*

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

*"ដើម្បីអនុវត្ត"*

- កាលប្បវត្តិ
- ឯកសារ នា.នីតិកម្ម/នា.សុខភាពសិក្សា